កាកបាទក្រហមកម្ពុជា

លេខ ២៧ កក្រក,ទទ

# សេចក្តីប្រកាសព័ត៌មាន

## ជំនួយមនុស្សធម៌បន្ទាន់ ជួយជនភៀសសឹកក្នុងស្រុក នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ

កាកបាទក្រហមកម្ពុជា (កក្រក) មានការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការផ្ទុះឡើងជាថ្មី នៃជម្លោះនៅតាមព្រំដែនកម្ពុជា-ថៃ ចាប់តាំងពីថ្ងៃទី ៧ ខែធ្នូ មក។ គិតត្រឹមម៉ោង ៧ ព្រឹក ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០២៥ មានគ្រួសារភៀសសឹកចំនួន ៥៧,០០០ គ្រួសារ ស្មើនឹងមនុស្សចំនួន ១៩២,១៧៣ នាក់ ត្រូវបានជម្លៀស រួមមានខេត្តឧត្តរមានជ័យ, ព្រះវិហារ, បន្ទាយមានជ័យ, បាត់ដំបង, ពោធិ៍សាត់, និងកោះកុង។ ជនស៊ីវិលចំនួន ១០នាក់បានស្លាប់ រាប់ទាំងទារកម្នាក់ (៤នាក់ នៅខេត្តឧត្តរមានជ័យ ម្នាក់នៅព្រះវិហារ និង៥នាក់ នៅបន្ទាយមានជ័យ)។

ដើម្បីសម្រាលទុក្ខលំបាករបស់ជនភៀសសឹក ទីស្នាក់ការកណ្តាល កក្រក បានផ្តល់ជំនួយសង្គ្រោះបន្ទាន់ដើម្បីជួយដល់គ្រួសារជនភៀសសឹកជាង ៧,០០០ គ្រួសារ នៅក្នុងតំបន់សុវត្ថិភាពចំនួនពីរ នៃស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ និងតំបន់សុវត្ថិភាពពីរ ផ្សេងទៀត នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។

កក្រក នឹងបន្តផ្តល់ជំនួយសង្គ្រោះ ដល់តំបន់សុវត្ថិភាពផ្សេងទៀត នៅថ្ងៃបន្ទាប់ នៃខេត្តដែលរងផលប៉ះពាល់ទាំងអស់។ ក្នុងពេលជាមួយគ្នានេះ បុគ្គលិក និងអ្នកស្ម័គ្រចិត្ត កក្រក នៅក្នុងសាខាខេត្តដែលរងផលប៉ះពាល់ទាំងអស់ បាននឹងកំពុងជួយប្រជាជន ក្នុងដំណើរការជម្លៀស, គ្រប់គ្រងជំរំ និងផ្តល់សេវាសង្គ្រោះបឋម ជូនអ្នកដែលត្រូវការចាំបាច់ និងផ្តល់សម្ភារអនាម័យដល់ស្ត្រី និងយកចិត្តទុកដាក់ចំពោះមនុស្សចាស់ជរា និងកុមារ។

កក្រក កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយ គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម (អាយ.ស៊ី.អរ.ស៊ី.) និងសហព័ន្ធអន្តរជាតិ (អាយ.អេស.អរ.ស៊ី) ដើម្បីចែករំលែក និងធ្វើបច្ចុប្បន្នភាពព័ត៌មានថ្មីៗ ក៏ដូចជាសូមអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវតែគោរពច្បាប់មនុស្សធម៌អន្តរជាតិ។ អាយ.ស៊ី.អរ.ស៊ី. ក៏បានចេញនូវសំណៅពិសេសលេខ ២ លើប្រធានបទពាក់ព័ន្ធដូចគ្នានេះ។

កាកបាទក្រហមកម្ពុជា សូមថ្លែងអំណរព្រះរាជគុណ ដ៏ខ្ពង់ខ្ពស់បំផុត ចំពោះ **ព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដែលព្រះអង្គបានប្រោសព្រះរាជទាន ព្រះរាជទ្រព្យ ជួយដល់ជនភៀសសឹក ក៏ដូចជាថ្លែងអំណរគុណ សប្បុរសជនទាំងអស់ពីគ្រប់មជ្ឈដ្ឋាន ដែលបានបរិច្ចាគទាំងសម្ភារៈ និងថវិកា ជូន កក្រក។

ឡូត៍ ១៦A ផ្លូវលេខ ៦៥២ កែង ២៧១ អូរបែកក្អម សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Lot : 16A, Street 652@271, O Bek Kaam, Sangkat Toek Laak 3, Khan Tuol Kork, Phnom Penh, Kingdom of Cambodia
Tel: (855-23) 881 511, Fax:(855-23) 881 522, P.O. Box: 69, Web: www.redcross.org.kh, Facebook: www.facebook.com/crcnhq, E-mail: info@redcross.org.kh, crc_adm@online.com.kh

ក្នុងកាលៈទេសៈ ដែលត្រូវការជំនួយមនុស្សធម៌ដ៏ចាំបាច់បំផុត សម្រាប់ជនភៀសសឹកកម្ពុជា ដែលកំពុងរងគ្រោះដោយសារសង្គ្រាមនេះ កក្រក សូមអំពាវនាវ **សម្តេច ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី និងសប្បុរសជាតិ អន្តរជាតិទាំងអស់** សូមមេត្តាចូលរួមបរិច្ចាគជាថវិកា ឬសម្ភារៈមកកក្រក ដើម្បីឱ្យសមាគមជាតិមានធនធាន និងលទ្ធភាពគ្រប់គ្រាន់ បន្តជួយជនភៀសសឹកដែលកំពុងត្រូវការជំនួយជាចាំបាច់។ កាកបាទក្រហមកម្ពុជា សង្ឃឹមយ៉ាងមុតមាំថា សប្បុរសជនគ្រប់មជ្ឈដ្ឋាននឹងបន្តគាំទ្រយើងខ្ញុំ ដោយស្មោះស្ម័គ្រក្នុងស្មារតីជាតិខ្មែរតែមួយ។

**សូមទំនាក់ទំនងព័ត៌មាន៖**

- **លោកជំទាវ ម៉ែន នារីសោភ័គ អគ្គលេខាធិការរងទី១**
  ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៨១០ ៨៥៤ អ៊ីមែល៖ sopheak.menneary@redcross.org.kh
- **ឯកឧត្តម យូ ឡាណា អគ្គលេខាធិការរងទី២**
  ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ២៨៩ ៥៧៦ អ៊ីមែល៖ you.lana@redcross.org.kh
- **លោកជំទាវ ហួន ចន្ទបូរ៉ា នាយិកា នាយកដ្ឋានទំនាក់ទំនង**
  ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៣១១ ៦១១ អ៊ីមែល៖ huonchanbora@redcross.org.kh

ភ្នំពេញថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០២៥

CAMBODIAN RED CROSS